# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី១ ឆ្នាំ២០០៨

របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

(១១/១២/២០០៧–៣០/៦/២០០៨)

ក្នុងឆមាសទី១ឆ្នាំ២០០៨នេះ អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តយកចិត្តទុកដាក់សហការ និងសម្របសម្រួលជាមួយក្រសួង–ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិក៏ដូចអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា អនុវត្តនូវ គោលនយោបាយ និង យុទ្ធសាស្ត្រ ដែលមានចែងនៅក្នុងផែនការសកម្មភាពឆ្នាំ២០០៨ សំដៅទប់ស្កាត់និងកាត់បន្ថយបញ្ហាគ្រឿងញៀននិងរួមចំណែកក្នុងការរក្សាសន្តិ–សុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ជាពិសេសក្នុងឱកាសនៃយុទ្ធនាការឃោសនាបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ខាងមុខ ។ និយាយឡែក អង្គភាពអនុវត្តន៍ច្បាប់គ្រប់ផ្នែកក៏បានបន្តយកចិត្តទុកដាក់លើកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនយ៉ាងសកម្ម ។ តាមរយៈកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសនេះ យើងក្តាប់បាននូវសភាពការណ៍គ្រឿងញៀនដូចតទៅ :

## I / <u>សភាពការណ៍គ្រឿងញៀនទូទៅ</u> :

### ១-ការផលិត

បន្ទាប់ពីបង្ក្រាបចំគោលដៅផលិតគ្រឿងញៀនសំយោគពីរករណីធំៗ ដោយកងកម្លាំងនគរបាលជាតិ**កាលពីថ្ងៃទី០១ខែមេសាឆ្នាំ២០០៧** និងដោយកងរាជអាវុធហត្ថលើផ្ទៃប្រទេស**កាលពីថ្ងៃទី០១ខែសីហាឆ្នាំ២០០៧** យើងបានកត់សំគាល់ឃើញការផលិតគ្រឿងញៀនសំយោគមិនមានសកម្មភាពជាទ្រង់ទ្រាយធំទេ ប៉ុន្តែការផលិតក្លែងក្លាយនិងកែច្នៃគុណភាពនូវគ្រឿងញៀនប្រភេទនេះ (ពិសេសមេតំហ្វេ–តាមីនគ្រាប់) នៅតែបន្តលបលួចផលិតដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក ។ ការផលិតធ្វើឡើងដោយពុម្ពកែច្នៃ ដែលក្នុងឆមាសទី១ឆ្នាំ២០០៨នេះ យើងបានរកឃើញចំនួន២លើកនៅទីក្រុងភ្នំពេញ ។

**២-ការចរាចរណ៍ចែកចាយ**

ទោះមានការផលិតក្លែងក្លាយនិងកែច្នៃគុណភាពក៏ពិតមែន ប៉ុន្តែ**ហេរ៉ូអ៊ីន** មេតំហ្វេតាមីនគ្រាប់ មេតំហ្វេតាមីនទឹកកក (**ICE**) នៅតែបន្តនាំមកពីតំបន់ត្រីកោណមាសដោយឆ្លងកាត់បណ្តាខេត្តព្រំដែនភាគខាងជើងប្រទេស (ពិសេសខេត្តស្ទឹងត្រែង) ។ **កត់សំគាល់** ការចរាចរ**មេតំហ្វេតាមីនគ្រាប់** មានគោលដៅខុសគ្នាពីការចរាចរ **មេតំហ្វេតាមីន ICE** និង **ហេរ៉ូអ៊ីន** ។

**មេតំហ្វេតាមីនគ្រាប់** ដែលនាំចូលតាមច្រកផ្លូវទឹកនិងផ្លូវគោកពីខេត្តស្ទឹងត្រែងកាត់បណ្តាខេត្តតាមដងទន្លេមេគង្គ គឺឆ្ពោះមកទីក្រុងភ្នំពេញដើម្បីចែកចាយទៅបណ្តាខេត្តផ្សេងៗ និងមួយចំនួននាំទៅបណ្តាខេត្តព្រំដែនភាគពាយ័ព្យ ។ ច្រកមួយទៀត គឺចូលតាមខេត្តព្រះវិហារ ឆ្លងកាត់ខេត្តឧត្តរមានជ័យ សំដៅទៅខេត្តបន្ទាយមានជ័យតែម្តង ។

ដោយឡែក **មេតំហ្វេតាមីនទឹកកក** (**ICE**) និង**ហេរ៉ូអ៊ីន** ភាគច្រើនការដឹកជញ្ជូនមានលក្ខណៈជាអន្តរជាតិច្រើនជាងការចរាចរនៅក្នុងស្រុក ដោយដឹកជញ្ជូនចេញពីកម្ពុជាតាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ ក្នុងឆមាសទី១ឆ្នាំនេះ មានហេរ៉ូអ៊ីនមួយករណីបាននាំឆ្លងកាត់តាមច្រកនេះ ដោយឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិដែលប្រើប្រាស់លិខិតឆ្លងដែនសញ្ជាតិតៃវ៉ាន់ ។ បើប្រៀបធៀបឆមាសទី១ឆ្នាំ២០០៧គឺមានការថយចុះ ប៉ុន្តែគោលដៅនៃការនាំចេញ និង អត្តសញ្ញាណឧក្រិដ្ឋជនគ្រឿងញៀនពុំមានការផ្លាស់ប្តូរឡើយ ។

**៣-ការប្រើបំពានគ្រឿងញៀន**

មេតំហ្វេតាមីន នៅតែជាប្រភេទគ្រឿងញៀនដែលនិយមប្រើច្រើនជាងគេ ក្នុងចំណោមពលរដ្ឋកម្ពុជា (ពិសេសក្នុងស្រទាប់យុវវ័យ) ។ តាមរយៈលទ្ធផលនៃការធ្វើអង្កេតលើឥរិយាបថអ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់គេ នៅក្នុងឃុំចំនួន៦០របស់ខេត្ត-ក្រុងចំនួន១២ ដែលទទួលរងផលប៉ះពាល់គ្រឿងញៀនធ្ងន់ធ្ងរបានបង្ហាញថា ប្រភេទគ្រឿងញៀនដែលពួកគេបានប្រើប្រាស់មានមេតំហ្វេតាមីនគ្រាប់, មេតំហ្វេតាមីនប្រភេទទឹកកក (**ICE**), កញ្ឆា, ហេរ៉ូអ៊ីន, កេតាមីន, កាវហិត, អាភៀន, អ៊ិចស្តាស៊ី ។ អ្នកប្រើគ្រឿងញៀនទាំងនោះភាគច្រើនជា កម្មករ កសិករ អ្នកគ្មានការងារធ្វើ ជាងឈើ និស្សិត អ្នកនៅផ្ទះ អ្នករត់ម៉ូតូឌុប អាជីវករ កម្មករកាត់ដេរ អ្នកនេសាទ អ្នកធ្វើការនៅកន្លែងកំសាន្តមួយចំនួន ។ លទ្ធផលអង្កេតបានបង្ហាញផងដែរថា ការយល់ដឹងពីការឆ្លងមេរោគអេដស៍នៅមានកំរិតទាប ទាំងក្នុងចំណោមអ្នកប្រើគ្រឿងញៀន ទាំងក្នុងចំណោមដៃគូរួមភេទរបស់គេ ។

## II / <u>**លទ្ធផលនៃកិច្ចប្រតិបត្តិការ**</u> :

**១-ការងារអនុវត្តច្បាប់**

**១.១-ការងារបង្ក្រាបបទល្មើស**

ក្នុងឆមាសទី១ឆ្នាំ២០០៨នេះ អង្គភាពអនុវត្តន៍ច្បាប់គ្រប់ផ្នែកបានបន្តយកចិត្តទុកដាក់បង្ក្រាបបទ

ល្មើសគ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម ៖

➥**បទល្មើស** បង្ក្រាបបាន **៩៧** ករណី (ឆមាសទី១ឆ្នាំ២០០៧ មាន **៩០** ករណី)

➥**ឃាត់ខ្លួនជនល្មើស** **១៩៤** នាក់ ក្នុងនោះបាញ់ស្លាប់**១**នាក់, បញ្ជូនទៅតុលាការ**១៩៣**នាក់ (ឆមាសទី១ឆ្នាំ២០០៧ មាន **១៦៦** នាក់ )

➥**វត្ថុតាងដកហូត** រួមមាន ៖

–**មេតំហ្វេតាមីនគ្រាប់ ៩៤.៧៦០** គ្រាប់ (ឆមាសទី១/២០០៧ មាន **១៤៩.១៤២** គ្រាប់)

–**មេតំហ្វេតាមីនICE ៥៣៤,១១** ក្រាម + **១៥** កូនកញ្ចប់ (ឆមាសទី១/២០០៧ មាន ៤.៨១៦,៥០ ក្រាម)

–អ៊ិចស្តាស៊ី **១៦** គ្រាប់ (ឆមាសទី១/២០០៧ មាន **៣០០** គ្រាប់)

–**ហេរ៉ូអ៊ីន ២,១៥២** គ.ក្រ (ឆមាសទី១/២០០៧ មាន **៨,១៩០** គ.ក្រ)

–កញ្ឆាក្រៀម **២,៣០** គ.ក្រ (ឆមាសទី១/២០០៧ មាន **១០** គ.ក្រ)

–កូដេអ៊ីន (ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ) ចំនួន **១០.១៦១** គ្រាប់ និងវត្ថុតាងពាក់ព័ន្ធជាច្រើនផ្សេងទៀត ។

**១.២-លទ្ធផលវិភាគសំណាកវត្ថុតាង**

មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អជបគញ បានទទួលធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលតុលាការនិងអង្គភាពអនុវត្តន៍ច្បាប់គ្រប់ផ្នែកបញ្ជូនមកមានចំនួន**១០៧**សំណាក ។

លទ្ធផលនៃការធ្វើកោសល្យវិច័យបានបង្ហាញដូចខាងក្រោម ៖

–សំណាក **អវិជ្ជមាន** ចំនួន **២២** សំណាក

–សំណាក **វិជ្ជមាន** ចំនួន **៨៥** សំណាកគឺ កញ្ឆា **១** សំណាក, **MDMA** (អ៊ិចស្តាស៊ី) **៤** សំណាក, មេតំហ្វេតាមីនទឹកកក(**ICE**) **២៦** សំណាក, មេតំហ្វេតាមីនគ្រាប់ **៤៥** សំណាក, ហេរ៉ូអ៊ីន **៥** សំណាក, (ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ៖ **Codeine** **២** សំណាក, **Ketamine** **១** សំណាក), **Psedeoephedrine** (សារធាតុគីមីផ្សំគ្រឿងញៀនសំយោគ**ATS**) **១** សំណាក ។

ក្រៅពីការងារកោសល្យវិច័យលើសំណាកវត្ថុតាងអគ្គលេខាធិការដ្ឋាន អជបគញ បាន ៖

–ទទួលសម្ភារៈជំនួយនៃគំរោងសហប្រតិបត្តិការតំបន់ របស់អង្គការ**JICA**ជប៉ុន សំរាប់ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន និង ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ តាមរយៈការប្រើប្រាស់នូវលទ្ធផលនៃការវិភាគលើលក្ខណៈរូបនិងភាពសុទ្ធនៃគ្រឿងញៀន (ថ្ងៃទី២៥/០១/២០០៨) ។

–ទទួលជញ្ជីងអេឡិចត្រូនិចសំរាប់ថ្លឹងគ្រឿងញៀន ដែលជាសម្ភារៈជំនួយនៃគំរោងសហប្រតិ–បត្តិការទ្វេភាគី អជបគញ–**JICA** ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។ ជញ្ជីងនេះបានផ្តល់ជូនក្នុងឱកាសនៃកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត–ក្រុង(២១/៥/២០០៨) ដល់ខេត្តក្រុងចំនួន១៨គឺ ក្រុងភ្នំពេញ, ក្រុងព្រះសីហនុ, ក្រុងប៉ៃលិន, ខេត្តបាត់ដំបង, បន្ទាយមានជ័យ, ស្ទឹងត្រែង,

ក្រចេះ, កំពង់ចាម, កំពង់ធំ, កណ្តាល, ព្រះវិហារ, សៀមរាប, ស្វាយរៀង, ព្រៃវែង, តាកែវ, កំពង់ស្ពឺ, កំពត, កោះកុង និងមន្ទីរប្រឆាំងគ្រឿងញៀន**១**គ្រឿង, កងរាជអាវុធហត្ថលើផ្ទៃប្រទេស **១**គ្រឿង, អង្គភាពគយ-រដ្ឋាករច្រកព្រលានយន្តហោះអន្តរជាតិ ក្រុងភ្នំពេញ ខេត្តសៀមរាប ក្រុងព្រះសីហនុ ចំនួន**៣**គ្រឿង ។

**១.៣-លទ្ធផលបំផ្លាញវត្ថុតាងគ្រឿងញៀន**

-ស្នងការដ្ឋាននគរបាលខេត្តក្រចេះ បានធ្វើការកាប់បំផ្លាញដំណាំកញ្ឆាលើផ្ទៃដី ១០១,៦ ម² ។

-ខេត្តពោធិសាត់ បង្ក្រាបកន្លែងលួចលាក់ស្តុកប្រេងម្រះព្រៅនៅក្នុងភូមិពីរស្ថិតក្នុងឃុំវាលរាម ស្រុកវាលវែង និងដកហូតបានប្រេងម្រះព្រៅចំនួន ២៥ តោន ។

-ខេត្តកំពង់ចាម បានបំផ្លាញសារធាតុគីមីផ្សំ (**Methylene Chloride.MC**) ចំនួន ៣.១១០ គ.ក្រ ។

-តាមរយៈ ការឧបត្ថម្ភគាំទ្រទាំងថវិកានិងបច្ចេកទេសពីស្ថាប័នប៉ូលីសសហព័ន្ធអូស្ត្រាលី អគ្គលេខាធិការដ្ឋាន អជបគញ បានដំណើរការដុតបំផ្លាញប្រេងម្រះព្រៅភ្នំចំនួន**១.២៨៥**បីដុង និង២០០លីត្រ (ខេត្តកំពត ៧៦បីដុង, ខេត្តបាត់ដំបង ១២៣បីដុង, ខេត្តពោធិសាត់ ១.០៨៦បីដុង និង២០០លីត្រ) សរុបទាំងអស់ប្រហែល **៣៥** តោន ។ ពិធីនេះ ប្រារព្ធធ្វើនៅភូមិទួលគ្រួស ឃុំចំរើនផល ស្រុកសំពៅមាស ខេត្តពោធិសាត់ (ពីថ្ងៃទី១៦រហូតដល់ថ្ងៃទី២០ខែមិថុនាឆ្នាំ២០០៨) ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិត **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ, ឯកឧត្តម **តេង សាវង្ស** អនុប្រធានអចិន្ត្រៃយ៍ អជបគញ, ឯកឧត្តម **លួ រ៉ាមីន** អគ្គលេខាធិការ អជបគញ និងអញ្ជើញចូលរួមជាកិត្តិយសមាន ឯកឧត្តម **ឌី សុគន្ធ** ប្រធានរដ្ឋបាលព្រៃឈើ, លោកស្រី **FIONA COCHAUD** តំណាងស្ថានទូតសហព័ន្ធអូស្ត្រាលីប្រចាំនៅកម្ពុជា, ឯកឧត្តម **ឆាយ សារ៉េត** អភិបាលខេត្តពោធិសាត់ ព្រមទាំងនាយខណ្ឌរដ្ឋបាលព្រៃឈើទាំង៣ខេត្ត និងអ្នកកាសែតជាតិ អន្តរជាតិជាច្រើនរូប ។

-សាលាក្រុងភ្នំពេញ បានធ្វើការដុតបំផ្លាញវត្ថុតាងគ្រឿងញៀន រួមមាន មេតំហ្វេតាមីនចំនួន **២៤៩.១២៤**គ្រាប់, មេតំហ្វេតាមីនទឹកកក **១៧.៥៨២,១៧**ក្រាម, ថ្នាំគ្រវីក្បាល **៣៣២**គ្រាប់, អូផ្យូមអាល់កាឡូអ៊ីដ **១៦**គ្រាប់, ថ្នាំញៀនបន្ទះ **២៨០**គ្រាប់, ថ្នាំបន្សាប **៣**គ្រាប់, ហេរ៉ូអ៊ីន **១៣.៧៣៧,៦៨**ក្រាម, សារធាតុផ្សំ **២៤៥.២០០**ក្រាម, កញ្ឆាគ្រីប **៣៥០០**ក្រាម, កញ្ឆាក្រៀម **១.៤០០**ក្រាម, បារីកញ្ឆា **៤៥**ដើម (ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០០៨) ។

**១.៤-ការពង្រឹងសមត្ថភាពអនុវត្តច្បាប់**

ក្នុងឆមាសទី១ឆ្នាំ២០០៨នេះ អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តយកចិត្តទុកដាក់លើការងារពង្រឹងសមត្ថភាពអនុវត្តច្បាប់ទទួលបានលទ្ធផលគួរកត់សំគាល់ ទាំងក្នុងក្របខណ្ឌគំរោង និង ក្រៅក្របខណ្ឌគំរោង មានដូចតទៅ :

***គំរោងរបស់ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម អ.ស.ប (UNODC)***

-បានបើកសិក្ខាសាលាអន្តរក្រសួងពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយការអនុវត្តន៍ប្រកាសរបស់ក្រសួង

សុខាភិបាល ស្តីពីការដាក់បញ្ចូលប្រេងម្រះព្រៅភ្នំទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២៧/១២/២០០៧) ។ បន្ទាប់មក នៅថ្ងៃទី០៥-០៦/៣/២០០៨ បានបើកសិក្ខាសាលា ដើម្បីពិនិត្យកែសំរួលលើសេចក្តីព្រាងគោលការណ៍ណែនាំសំរាប់ការត្រួតពិនិត្យប្រេងម្រះព្រៅភ្នំ និងដាក់ចេញនូវវិធានការដាក់ស្តែងសំរាប់ទប់ស្កាត់ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ ការរក្សាទុក និង ការធ្វើពាណិជ្ជកម្មក្នុងប្រទេសនិងអន្តរជាតិនូវប្រេងម្រះព្រៅភ្នំ ។

-បានបើកសិក្ខាសាលាអនុតំបន់ សំរាប់មន្ត្រីទំនាក់ទំនងព្រំដែន (**BLO**) ចំនួន៦ប្រទេសគឺ កម្ពុជា ឡាវ ថៃ វៀតណាម មីយ៉ាន់ម៉ា ចិន នៅខេត្តសៀមរាប (២៨-៣០/៤/២០០៨) ដើម្បីរៀបចំយុទ្ធសាស្ត្រត្រួតពិនិត្យគ្រឿងញៀនសំរាប់ឆ្នាំ២០០៨-២០១១ និងពិភាក្សាពីលទ្ធភាពទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងប្រទេស ដូចជា ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងការការពារបរិស្ថាន ដោយប្រើប្រាស់យន្តការនៃការិយាល័យ **BLO** ដែលមានស្រាប់នៅនឹងកន្លែង ។

**ក្រៅពីនោះ** តាមរយៈកិច្ចពិភាក្សាការងារជាមួយតំណាងអង្គការ**UNODC**តំបន់ (លោក **Akira Fujino**) អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តយកចិត្តទុកដាក់លើការចងក្រងឯកទេសនីតិវិធីតាមបទដ្ឋានបច្ចេកទេសដែលមានសុវត្ថិភាពសំរាប់ប្រតិបត្តិការបង្ក្រាបមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

***គំរោងសហប្រតិបត្តិការទ្វេភាគីជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)***

អគ្គលេខាធិការដ្ឋាន អជបគញ បានសម្របសម្រួលនិងសហការបើកសិក្ខាសាលាបានជាច្រើនវគ្គក្នុងនោះរួមមានសិក្ខាសាលាស្តីពី **១**)ការយល់ដឹងពីគ្រឿងញៀន (៣/១២/២០០៧), **២**)ការអនុវត្តន៍ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (១៧-២២/១២/២០០៧), **៣**)ការធ្វើតេស្តគ្រឿងញៀនជំហានដំបូង (២៥/៤/២០០៨), **៤**)ការផ្លាស់ប្តូរបទពិសោធន៍លើការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀន (២៦-២៧/០២/២០០៨), **៥**)ការប្រើប្រាស់ព័ត៌មានវិភាគគ្រឿងញៀន (២៨២៩/០២/២០០៨), **៦**)ចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន, **៧**)ការស៊ើបអង្កេតគ្រឿងញៀន, **៨**)ការវិភាគគ្រឿងញៀន, **៩**)ការប្រមូលព័ត៌មានគ្រឿងញៀន (០៩-១៣/៦/២០០៨) ។ មន្ត្រីដែលទទួលការបណ្តុះបណ្តាលលើជំនាញទាំងអស់នោះរួមមាន នាយនិងពលនគរបាលគ្រប់ខេត្ត-ក្រុង, មន្ត្រីគយ-រដ្ឋាករ, មន្ត្រីកាំកុងត្រូល, មន្ត្រីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលដែលប្រចាំការច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ខេត្តសៀមរាប, ព្រះរាជអាជ្ញានៃខេត្ត-ក្រុងសំខាន់ៗ, កងរាជអាវុធហត្ថ, មន្ត្រីក្រសួងយុត្តិធម៌ និង មន្ត្រីអគ្គលេខាធិការដ្ឋាន ។

ដើម្បីអនុវត្តបន្ត**គំរោងសហប្រតិបត្តិការទ្វេភាគីជាមួយអង្គការJICA** ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា (សំរាប់ឆ្នាំទី២) នៅថ្ងៃទី២៧ខែឧសភាឆ្នាំ២០០៨ ក្រុមការងារគំរោងបានប្រជុំជាមួយតំណាងអង្គការ**JICA**ប្រចាំនៅកម្ពុជា ដើម្បីត្រួតពិនិត្យការអនុវត្តន៍ផែនការសកម្មភាពនៃគំរោងកន្លងមកនិងកែលំអរសកម្មភាពលើការងារផ្សព្វផ្សាយអប់រំ, ការពង្រឹងសមត្ថភាពអនុវត្តច្បាប់, ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន ក្នុងទិសដៅអនុវត្តគំរោងនេះបន្តចាប់ពីខែមេសាឆ្នាំ២០០៨ ដល់

ខែមីនាឆ្នាំ២០០៩ ។

**ដោយឡែក**នៅថ្ងៃទី០៥/៥/២០០៨តាមរយៈកិច្ចពិភាក្សាការងារជាមួយមន្ត្រីជាន់ខ្ពស់ផ្នែកគោលនយោបាយសាធារណៈនិងកម្មវិធីរបស់អង្គការ**JICA**នៅទីក្រុងតូក្យូ បានពិនិត្យលទ្ធភាពជួយដល់អគ្គលេខាធិការដ្ឋាន អជបគញ លើការងារសំខាន់ពីរគឺ **១)** ធ្វើការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជានៅឯប្រទេសជប៉ុន និង បញ្ជូនអ្នកឯកទេសពីប្រទេសជប៉ុនមកធ្វើការហ្វឹកហ្វឺនដល់មន្ត្រីអនុវត្តច្បាប់នៅកម្ពុជាលើមុខជំនាញវិភាគគ្រឿងញៀន, ជំនាញត្រួតពិនិត្យគ្រឿងញៀនតាមច្រកទ្វារអន្តរជាតិ ពិសេសបច្ចេកទេសបង្ក្រាបបទល្មើសគ្រឿងញៀន **២)** ពិនិត្យលទ្ធភាពក្នុងការជួយបង្កើតមន្ទីរពិសោធន៍គ្រឿងញៀនខ្នាតតូចនៅក្នុងខេត្តភាគពាយ័ព្យ និង ឥសានប្រទេស ។

***គំរោងសហប្រតិបត្តិការទ្វេភាគី ជាមួយ សាធារណរដ្ឋកូរ៉េ***

ដើម្បីចាប់ផ្តើមកិច្ចសហប្រតិបត្តិការជាមួយភាគីកូរ៉េ អគ្គលេខាធិការដ្ឋាន អជបគញ បានសំរបសំរួលជូនអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ក្នុងការបើកការិយាល័យទំនាក់ទំនង (ហៅថា **LOICOG**) ដើម្បីដំណើរការអនុវត្តគំរោង " ស្តីពីការផ្តល់សមត្ថភាពជំនាញត្រួតពិនិត្យគ្រឿងញៀនដល់មន្ត្រីអនុវត្តច្បាប់នៅបណ្តាប្រទេសក្នុងសមាគមអាស៊ាន "សំរាប់ប្រទេសកម្ពុជា ហើយភាគីកូរ៉េបានផ្តល់នូវសម្ភារៈមួយចំនួនសំរាប់កិច្ចដំណើរការអនុវត្តគំរោងនោះ នៅថ្ងៃទី២៥ខែមីនាឆ្នាំ២០០៨ ។

***កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយសាធារណរដ្ឋបារាំង***

អគ្គលេខាធិការដ្ឋាន បានទទួលការគាំទ្រលើការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន, ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់និងការងារលើកកំពស់ការយល់ដឹងពីគ្រឿងញៀន ។

**ទន្ទឹមនោះ** ដោយបានការអនុញ្ញាតពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ និងបានការអញ្ជើញពីភាគីបារាំង ឯកឧត្តម **គេង សាវឌ្ឍ** អនុប្រធានអចិន្ត្រៃយ៍ អជបគញ បានដឹកនាំប្រតិភូទៅទស្សនកិច្ចសិក្សាស្វែងយល់និងដកបទពិសោធន៍អំពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់អង្គភាពបេសកកម្មជាតិត្រួតពិនិត្យសារធាតុគីមីផ្សំ នៃសាធារណរដ្ឋបារាំង ។

***កិច្ចសហប្រតិបត្តិការទ្វេភាគី អជបគញ-ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)***

អគ្គលេខាធិការដ្ឋាន អជបគញ បានទៅចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅខេត្តនគររាជសីមាប្រទេសថៃ ០៥-០៨/០២/២០០៨ ។ កិច្ចប្រជុំបានឯកភាពគ្នា **១)**នឹងរៀបចំឱ្យមានកិច្ចប្រជុំត្រីភាគី កម្ពុជា-ថៃ-ឡាវ ដោយភាគីថៃនឹងធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំលើកដំបូង **២)**ភាគីថៃបានជួយកម្ពុជាក្នុងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់និងមន្ត្រីទំនាក់ទំនងព្រំដែន (**BLO**) របស់ខេត្តឧត្តរមានជ័យចំនួន២០នាក់, ខេត្តព្រះវិហារចំនួន១០នាក់ (២៦-៣០/៥/២០០៨) នៅខេត្តនគររាជសីមាប្រទេសថៃ **៣)** ជួយបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (**BLO**) រវាងខេត្តព្រះវិហារ ជាមួយខេត្តអ៊ូប៊ុន (ប្រទេសថៃ) **៤)** ផ្តល់កាណូតប្រដេញចំនួន២គ្រឿងដល់ខេត្តស្ទឹងត្រែងសំរាប់កិច្ចប្រតិបត្តិការល្បាតតាមដងទន្លេមេគង្គ **៥)** បន្តពង្រឹងកិច្ចសហការផ្តល់ព័ត៌-

មានគ្រឿងញៀនទៅវិញទៅមកឱ្យកាន់តែល្អប្រសើរ ។

តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (**ONCB**) អគ្គលេខាធិការដ្ឋាន អជបគញ ទទួលបានការឧបត្ថម្ភពីភាគីថៃនូវប៉ាណូចំនួន៤ផ្ទាំង ដែលមានខ្លឹមសារផ្សព្វផ្សាយអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅព្រះរាជាណាចក្រកម្ពុជា និង ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅព្រះរាជាណាចក្រថៃ សំរាប់ដាក់នៅច្រក **ចាំយាម** (ខេត្តកោះកុង) ច្រក **ព្រំ** (ក្រុងប៉ៃលិន) ច្រក **ដូង** (ខេត្តបាត់ដំបង) និងច្រក **ប៉ោយប៉ែត** (ខេត្តបន្ទាយមានជ័យ) ។

**ថ្មីៗនេះ** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ បានជួបជាមួយឯកឧត្តម **Sampong Amornvivat** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជា (១៨/៦/២០០៨) ។ ឯកឧត្តម **Sampong Amornvivat** បានជំរាបពីជំហររបស់រដ្ឋាភិបាលថៃក្នុងការរឹតចំណងសាមគ្គីភាព កិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរ និងការត្រៀមលក្ខណៈជាស្រេចដើម្បីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជា, ការផ្តល់នូវសម្ភារៈសំរាប់កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស រួមទាំងជំនួយផ្នែកកិច្ចការច្បាប់ផង ។

### ២-ការពង្រឹងអគ្គលេខាធិការដ្ឋាន អជបគញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង

#### *ក-ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ*

តាមរយៈកិច្ចពិភាក្សាការងារជាមួយលោក **Akira Fujino** តំណាងការិយាល័យ**UNODC**តំបន់ អគ្គលេខាធិការដ្ឋាន អជបគញ បានសំណូមពរឱ្យ**UNODC** បន្តយកចិត្តទុកដាក់ពង្រឹងកិច្ចសហការក្នុងការអនុវត្តន៍គំរោងស្តីពីការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ (គំរោង**J11**) ដែលគំរោងនេះនៅមានសេសសល់កិច្ចការមួយចំនួនត្រូវធ្វើបន្តទៀត ។

#### *ខ-ការពង្រឹងរចនាសម្ព័ន្ធរដ្ឋបាលត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង*

នៅថ្ងៃទី២១ខែឧសភាឆ្នាំ២០០៨ អគ្គលេខាធិការដ្ឋាន អជបគញ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ។ នៅក្នុងកិច្ចប្រជុំនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន អជបគញ បានណែនាំដូចតទៅ :

១-ត្រូវបន្តមានវិធានការជាបន្ទាន់ចំពោះតំបន់ទាំងឡាយ ដែលមានសកម្មភាពលក់ចែកចាយ និងប្រើប្រាស់ដើម្បីកាត់បន្ថយភាពអនាធិបតេយ្យ, អសន្តិសុខក្នុងមូលដ្ឋាននិងសណ្តាប់ធ្នាប់សាធារណៈ។

២-ត្រូវបន្តក្តាប់មុខសញ្ញាប្រព្រឹត្តបទល្មើស និងធ្វើការប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀនឱ្យបានច្បាស់លាស់ ដើម្បីឈានទៅអនុវត្តឱ្យបានជោគជ័យនូវគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣-ត្រូវបន្តជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ពីប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីពង្រឹងនិងពង្រីកយន្តការផ្សព្វផ្សាយអប់រំ ឱ្យកាន់តែមាននិរន្តរភាព និង

វិសាលភាពទូលំទូលាយជ្រួតជ្រាបដល់គ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ ។ ចំពោះក្រុមការងារបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅក្នុងសាលារៀនដែលអាជ្ញាធរជាតិបានណែនាំឱ្យបង្កើត ខេត្ត-ក្រុងទាំងឡាយណាដែលមិនទាន់បានបង្កើតត្រូវរូតរះបង្កើតឡើង និងចាប់ផ្តើមអនុវត្តឱ្យបានឆាប់រហ័ស ។

៤-ចំពោះខេត្តក្រុង ដែលមិនទាន់បានបង្កើតមជ្ឈមណ្ឌលសំរាប់ព្យាបាលអ្នកញៀនគ្រឿងញៀន ត្រូវពិចារណារកកន្លែងទុកដាក់អ្នកទាំងនោះ ក្នុងគោលបំណងលើកកំពស់សុខុមាលភាពជនរងគ្រោះ និងរួមចំណែកក្នុងការរក្សានូវសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាពសង្គមក្នុងខេត្ត-ក្រុងរបស់ខ្លួន ។

៥-ចំពោះខេត្ត-ក្រុង ដែលមិនទាន់មានលេខាធិការដ្ឋាន ឬមិនទាន់បានជ្រើសរើសមន្ត្រីឱ្យមកបំរើការងារជាប្រចាំនៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ត្រូវរៀបចំបង្កើត និងរៀបចំរចនាសម្ព័ន្ធ របៀបរបបការងារ ក្នុងលេខាធិការដ្ឋានឱ្យបានល្អប្រសើរ ។

ចំពោះបញ្ហាថវិកាសំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់ខេត្ត-ក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសំរេចផ្តល់ជូនខេត្ត-ក្រុង នូវថវិកាក្នុងចំនួនសមស្របដែលអាចអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងឆ្នាំ២០០៨ ។ នៅក្នុងឱកាសនៃកិច្ចប្រជុំ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានផ្តល់ប័ណ្ណសរសើរជូនដល់ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់ខេត្ត-ក្រុង និងអង្គភាពជំនាញ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, កងរាជអាវុធហត្ថលើផ្ទៃប្រទេស និង អង្គភាពគយ-រដ្ឋាករ ។

### ៣-ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន

#### ៣.១-សកម្មភាព ផ្សព្វផ្សាយ អប់រំ

#### *ក-កម្មវិធីផ្សព្វផ្សាយ អប់រំ តាមគោលដៅ*

កិច្ចការនេះ អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងស្ថាប័នរាជរដ្ឋាភិបាល, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់ខេត្ត-ក្រុង, អង្គការជាតិ និងអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាលជាដៃគូនានា ដូចជា :

-សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅវិទ្យាល័យ១០មករា (ខេត្តសៀមរាប) ដែលមានសមាជិកចូលរួមចំនួន ១.២០០ នាក់ និង នៅស្រុកស្ទឹងត្រែង (០៤/២/០៨) និងស្រុកសៀមបូក (០៥/២/០៨) ។

-សម្របសម្រួលនិងផ្តល់ឯកសារជូនគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបាត់ដំបង ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង គ្រោះថ្នាក់នៃគ្រឿងញៀន ដល់លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន១៣លើក នៅស្រុកបាត់ដំបង ស្រុកបាណន់ ស្រុកថ្មគោល ស្រុកកំរៀង ស្រុកសំឡូត ស្រុកភ្នំព្រឹក និងបានសហការជាមួយអង្គការប្រតិបត្តិការកុមារកម្ពុជា ១លើក មានសមាជិកចូលរួមចំនួន ២.៦២០ នាក់ ។

-សម្របសម្រួលនិងផ្តល់ឯកសារជូនគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តក្រចេះ ដើម្បីសហការជាមួយអង្គការ**ESCUP** ធ្វើការអប់រំផ្សព្វផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងពីគ្រោះថ្នាក់នៃ

គ្រឿងញៀន ដល់កម្លាំងស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលស្រុកស្អាង លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្សនៅវិទ្យាល័យ និងអនុវិទ្យាល័យចំនួន៧ក្នុងស្រុកស្អាង សរុបមានចំនួន ៣៨២ នាក់ ។

-សហការនិងបំផុសគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់ខេត្ត-ក្រុង ឱ្យចូលរួមប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០០៨ ដែលមានប្រជាជនចូលរួមសរុបប្រមាណជាង ២០.០០០ នាក់ ។ កត់សំគាល់ ទិវាឆ្នាំនេះនៅទីក្រុងភ្នំពេញបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដែលមានមហាជនចូលរួមប្រមាណ ១០.០០០ នាក់ ។

-អគ្គលេខាធិការដ្ឋាន អជបគញ បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់របស់កាកបាទក្រហមកម្ពុជា ជាមួយកាស៊ីណូធំៗ "ស្តីពីការបង្ការមេរោគអេដស៍ ក្នុងចំណោមបុគ្គលិកកាស៊ីណូ" ដើម្បីលើកកំពស់ការយល់ដឹងពីជម្ងឺអេដស៍និងវិធានការការពារក្នុងចំណោមបុគ្គលិកកាស៊ីណូ ។

### ខ-វគ្គបណ្តុះបណ្តាលលើកកំពស់ការយល់ដឹងពីគ្រឿងញៀន

-សហការជាមួយគំរោងទ្វេភាគី អជបគញ-**JICA** បើកវគ្គបណ្តុះបណ្តាលស្តីពីការលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់នៃគ្រឿងញៀន(២៥-២៨/១២/២០០៧) ដល់មន្ត្រីដែលមកពីក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច ក្រសួងអប់រំយុវជននិងកីឡា ក្រសួងវប្បធម៌ ក្រសួងធម្មការនិងសាសនា ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងសុខាភិបាល និងសាលាក្រុងភ្នំពេញ ។

-តាមរយៈជំនាញការអាល្លឺម៉ង់ សហការជាមួយសមាគមអភិវឌ្ឍន៍ព្រះពុទ្ធសាសនានិងសង្គម បើកសិក្ខាសាលាស្តីពីការលើកកំពស់សមត្ថភាពសហគមន៍ចងក្រងបណ្តាញប្រយុទ្ធប្រឆាំងការប្រើប្រាស់គ្រឿងញៀនតាមសហគមន៍(ខេត្តកំពង់ចាម ០៨/០១/២០០៨) ។

-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អង្គការ "កម្មវិធីបណ្តាញព័ត៌មាននិងសកម្មភាពត្រួតពិនិត្យគ្រប់គ្រងការប្រើប្រាស់គ្រឿងញៀនក្នុងតំបន់" (**IOGT-RIANDAC**)នៅកម្ពុជា ឆ្នាំទី១ ដំណាក់ កាលទី២(២០០៧-២០០៩) ។ ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារនេះ តាមការស្នើសុំរបស់អង្គការ**IOGT-RIANDAC** អគ្គលេខាធិការដ្ឋាន អជបគញ បានជូនប័ណ្ណសរសើរចំនួន៨ ដល់ស្រុកកណ្តាលស្ទឹង ឃុំគោកត្រប់ វិទ្យាល័យ ហ៊ុន សែន កំពង់កន្ទួត វិទ្យាល័យ ហ៊ុន សែន ជម្ពូវ័ន វិទ្យាល័យសន្ធរម៉ុក វិទ្យាល័យបឹងត្របែក វិទ្យាល័យព្រះយុគន្ធរ និងវិទ្យាល័យសាមគ្គី ជា ស៊ីម ដែលមានស្នាដៃក្នុងការអនុវត្តន៍កម្មវិធីនៃគំរោង ។ ដោយឡែក សមាគមយុវជនខ្មែរ ដែលជាដៃគូរបស់អង្គការ **IOGT-RIANDAC** ក៏បានបន្តការរៀបចំចងក្រងជាក្លឹបយុវវ័យ ដើម្បីដំណើរការបណ្តុះបណ្តាលលើការងារអប់រំបង្ការបញ្ហាគ្រឿងញៀននៅតាមវិទ្យាល័យ អនុវិទ្យាល័យ និង សាលាបឋមសិក្សាចំនួន១៤ នៅក្រុងភ្នំពេញ ខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន និង ខេត្តកណ្តាល ។

### គ-កម្មវិធីអប់រំ តាមប្រព័ន្ធផ្សព្វផ្សាយ

ដោយបានការគាំទ្រពីក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល បណ្តាស្ថានីយ៍វិទ្យុ-ទូរទស្សន៍ជាតិនិងឯក

ជន អគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយកម្មវិធីនានារបស់អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចកម្មវិធីនានារបស់អង្គការជាតិនិងអន្តរជាតិ ក្នុងការផ្តល់នូវបទសម្ភាសន៍ កម្មវិធីសំណួរ-ចម្លើយ តាមកម្មវិធីប្រចាំសប្តាហ៍ដែលបានគ្រោងទុក ដើម្បីលើកកំពស់ការយល់ដឹងអំពីគ្រឿងញៀន ។

ទន្ទឹមនោះ តាមរយៈ ÷

-ការឧបត្ថម្ភគាំទ្រពីសំណាក់អង្គការ**UNODC,** អង្គការសុខភាពពិភពលោក, អង្គការសុខភាពគ្រួសារអន្តរជាតិ, ការិយាល័យតំណាងអង្គការ**JICA**អមអគ្គលេខាធិការដ្ឋាន អជបគញ, ការិយាល័យទំនាក់ទំនងរបស់អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េអមអគ្គលេខាធិការដ្ឋាន អជបគញ (**LOICOG**) ,អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍ (**KHANA**) អគ្គលេខាធិការដ្ឋាន អជបគញ បានសហការផលិតនូវឯកសារផ្សព្វផ្សាយមួយចំនួនដូចជា ខិត្តប័ណ្ណ កូនសៀវភៅផ្ទាត់ **Poster** បដាកាន់ដៃ បដាចងតាមផ្លូវ មួក អាវយឺត សំរាប់ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ខែមិថុនាឆ្នាំ២០០៨ ។

-កិច្ចសហប្រតិបត្តិការជាមួយគំរោង**AusAID**របស់អូស្ត្រាលី អគ្គលេខាធិការដ្ឋាន អជបគញ បានសហការពិនិត្យនិងវាយតម្លៃ លើសេចក្តីព្រាងកម្មវិធីគំរោងសំរាប់តំបន់អាស៊ី **ស្តីពីបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀន** (គំរោង **HAARP**) ដែលមានវិសាលភាពអនុវត្តនៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ ក្នុងគោលបំណងលើកកំពស់ប្រសិទ្ធិភាពការងារពាក់ព័ន្ធនឹងដំណោះស្រាយនៃបញ្ហាគ្រឿងញៀន/អេដស៍នៅកម្ពុជា ។

### ៣.២-ការងារទិន្នន័យព័ត៌មានគ្រឿងញៀន

-តាមរយៈគំរោងទ្វេភាគី (គំរោង **AD/CMB/04/H83 . UNODC**) រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ ស្តីពីការអភិវឌ្ឍន៍សេវាប្រឹក្សា ព្យាបាល និង ស្តារនីតិសម្បទាផ្អែកលើសហគមន៍សំរាប់ការប្រើបំពានគ្រឿងញៀននៅកម្ពុជា បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ បានចំនួន១៥រូប, គ្រូបង្គោលថ្នាក់ខេត្តក្រុងចំនួន២៤រូប និងមន្ត្រីអនុវត្តន៍ (អ្នកបញ្ចូលទិន្នន័យ) ចំនួន២៥២រូប សំរាប់ធ្វើការអង្កេតលើឥរិយា-បថអ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់ពួកគេ នៅក្នុងឃុំចំនួន៦០របស់ខេត្ត-ក្រុងចំនួន១២ ដែលទទួលរងផលប៉ះពាល់គ្រឿងញៀនធ្ងន់ធ្ងរគឺ ភ្នំពេញ ព្រះសីហនុ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ចាម កណ្តាល សៀមរាប ស្ទឹងត្រែង ស្វាយរៀង និង កោះកុង ។

**លទ្ធផលនៃការអង្កេតក្នុង៦០ឃុំ**លើឥរិយាបថអ្នកប្រើគ្រឿងញៀនចំនួន ១.៤៦៥នាក់ (ស្ត្រី១២៧នាក់) ក្នុងនោះអ្នកប្រើគ្រឿងញៀនជាប្រចាំនិងមានលក្ខណៈធ្ងន់ធ្ងរមាន២៩៨នាក់ (ស្ត្រី២៤នាក់) ដែលក្នុងនោះ**អ្នកប្រើគ្រឿងញៀនដែលធ្លាប់ទទួលព័ត៌មានពីមេរោគអេដស៍**មាន ១.៣២៩ នាក់, ដៃគូរបស់ពួកគេមាន២១៩នាក់ និង**អ្នកប្រើគ្រឿងញៀនដែលធ្លាប់ទទួលព័ត៌មានពីអ្នកកើតជម្ងឺអេដស៍**មាន ១.៣១១ នាក់, ដៃគូរបស់ពួកគេ មាន ២១២ នាក់ ។

-តាមរយៈគំរោងទ្វេភាគី (គំរោង **J 11 . UNODC**) រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿង

ញៀន ជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ ស្តីពីការពង្រឹងសមត្ថ–ភាពអគ្គលេខាធិការដ្ឋាន អជបគញ បាននិងកំពុងរៀបចំធ្វើការផ្សព្វផ្សាយនូវរបាយការណ៍ឆ្នាំ២០០៧ ស្តីពីទិន្នន័យគ្រឿងញៀនខុសច្បាប់និងប្រព័ន្ធតាមដានជាប្រចាំនៅក្នុងប្រទេសកម្ពុជា ។

–តាមរយៈកិច្ចសហការជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិងកាមរោគ ក្រសួងសុខាភិបាល (**NCHADS**) បាននិងកំពុងបន្តធ្វើការវិភាគរបាយការណ៍ស្តីពីការអង្កេតពីអត្រានៃមេរោគអេដស៍ក្នុងចំណោមអ្នកប្រើគ្រឿងញៀន នៅតាមមណ្ឌលអប់រំកែប្រែអ្នកញៀនគ្រឿងញៀន ។

–តាមរយៈក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេដស៍ (**D/HA**) បាននិងកំពុងបន្តឆ្លងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិក្នុងការឆ្លើយតបចំពោះការប្រើបំពានគ្រឿញៀន និងការឆ្លងរាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ។

–តាមរយៈអង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌នៃអង្គការសហប្រជាជាតិ (**the United Nation Educational Scientific Cultural Organization. UNESCO)** ក្រុមការងាររបស់មជ្ឈមណ្ឌលព័ត៌–មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អជបគញ បានធ្វើការស្ទាបស្ទង់មួយដើម្បីយល់ដឹងកាន់តែច្បាស់ អំពីសេវាកម្មសំរាប់ជនរងគ្រោះដោយការប្រើបំពានគ្រឿងញៀនរបស់អង្គការមិនមែនរដ្ឋា–ភិបាលចំនួន៥៤ ដែលកំពុងធ្វើសកម្មភាពនៅក្នុងខេត្ត–ក្រុងចំនួន១៤គឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងប៉ៃលិន ខេត្តកំពង់ស្ពឺ ព្រៃវែង កំពង់ចាម ក្រចេះ កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និង កោះកុង (ពីខែឧសភាដល់ខែមិថុនាឆ្នាំ២០០៨) ។

–តាមរយៈវិទ្យាស្ថាន **BURNET** របស់ប្រទេសអូស្ត្រាលី អគ្គលេខាធិការដ្ឋាន អជបគញ បានចាត់បញ្ជូនមន្ត្រី៤រូបទៅចូលរួមក្នុងការបណ្តុះបណ្តាលស្តីពីការធ្វើអង្កេតលើការប្រើប្រាស់**ATS** សំរាប់អ្នកប្រើបំពានគ្រឿងញៀននៅ ក្នុង និង ក្រោមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅ ក្រុងភ្នំពេញ ខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ ។

### ៤–ការងារព្យាបាល និង ស្តារនីតិសម្បទា

បច្ចុប្បន្ន មានមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនចំនួន ១០ កន្លែង ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ រួមមាន :

**–ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា** ចំនួន ៤ កន្លែងគឺ មជ្ឈមណ្ឌលយុវនីតិសម្បទាចោមចៅ (ក្រុងភ្នំពេញ), មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ (ខេត្តបន្ទាយមានជ័យ), មជ្ឈមណ្ឌលជីវិតថ្មីស្មាច់មានជ័យ (ខេត្តកោះកុង), មជ្ឈមណ្ឌលយុវនីតិសម្បទាជីវិតថ្មីកំពង់កន្ទួត (ខេត្តកណ្តាល) ។

**–ក្រសួងសុខាភិបាល** ចំនួន ១ កន្លែង ជាមជ្ឈមណ្ឌលថ្នាក់ជាតិសំរាប់ព្យាបាលអ្នកជម្ងឺផ្លូវចិត្តនិងអ្នកញៀនគ្រឿងញៀននៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ–សូវៀត ។ បន្ថែមពីលើនោះគឺជាកន្លែងព្យាបាលអ្នកញៀនហេរ៉ូអ៊ីនដោយប្រើសារធាតុជំនួស (កម្មវិធីមេដាដូន) ដែលកំពុងរៀបចំដាក់ឱ្យដំណើរការ ។

**–សាលាក្រុងភ្នំពេញ** ចំនួន ១ កន្លែងគឺ មជ្ឈមណ្ឌល"ឱកាសខ្ញុំ" ស្ថិតនៅភូមិសែនសុខ សង្កាត់

ឃ្លួញ ខណ្ឌឫស្សីកែវ ។

**-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប** ចំនួន ១ កន្លែង ។

**-ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង** ចំនួន ១ កន្លែង ។

**-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ** ចំនួន ១ កន្លែង ។

**-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបង** ចំនួន ១ កន្លែង ។

ក្រៅពីនោះ នៅមានមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយឯកជននិងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត ។ មជ្ឈមណ្ឌលទាំង១០របស់រដ្ឋនិងមជ្ឈមណ្ឌល១របស់ឯកជន បានផ្ញើរបាយការណ៍បូកសរុបលទ្ធផលនៃការទទួលព្យាបាលអ្នកញៀន មកអគ្គលេខាធិការដ្ឋាន អជបគញ ដែលមានតួលេខសរុប ៨៣៥ នាក់(ស្ត្រី១១នាក់) ។

-តាមរយៈ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង បានបញ្ជូនរបាយការណ៍ទិន្នន័យការប្រើបំពានគ្រឿងញៀនប្រចាំឆ្នាំ២០០៧ និងឆមាសទី១ឆ្នាំ២០០៨ មកអគ្គលេខាធិការដ្ឋាន អជបគញ ដែលតួលេខអ្នកញៀនគ្រឿងញៀនសរុបមានចំនួន**៥.៧៩៧**នាក់(ស្ត្រី៣៧៧នាក់) ។ ក្នុងនោះអ្នកដែលបានចូលទៅកន្លែងព្យាបាលផ្តាច់គ្រឿងញៀនមានចំនួន **១.៧១៩** នាក់ ។

-តាមរយៈ ក្រុមការងារបច្ចេកទេសទទួលបន្ទុកកិច្ចការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បាននិងកំពុងបន្តការស្រាវជ្រាវរកវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទ ហេរ៉ូអ៊ីន និង **ATS** ។

ពាក់ព័ន្ធនឹងការព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន ក្រុមការងារអន្តរក្រសួង(ជាពិសេសក្រសួងសុខាភិបាល) បានតាក់តែងសេចក្តីព្រាងសេចក្តីណែនាំវេជ្ជសាស្ត្រស្តីពីការព្យាបាលបន្តដោយប្រើឱសថមេតាដូនរួចរាល់ និងកំពុងដាក់ជូនក្រសួងយុត្តិធម៌ពិនិត្យបន្ថែមលើទិដ្ឋភាពច្បាប់ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ពិនិត្យបន្ថែមលើការងារសង្គមកិច្ចនិងយុវនីតិសម្បទាដើម្បីស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាល និងឈានទៅរៀបចំគោលនយោបាយថ្នាក់ជាតិស្តីពីការព្យាបាលបន្តអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនដោយប្រើឱសថជំនួស ឬហៅថាកម្មវិធីមេតាដូន ។

-តាមរយៈ គំរោង **AD/CMB/04/H83(UNODC)** ស្តីពី **"ការអភិវឌ្ឍន៍សេវាប្រឹក្សា ព្យាបាល និង ស្តារនីតិសម្បទាផ្អែកលើសហគមន៍សំរាប់ការប្រើបំពានគ្រឿងញៀននៅកម្ពុជា"** បន្ទាប់ពីបានធ្វើការអង្កេតនិងវាយតម្លៃឆាប់រហ័ស **លើឥរិយាបថអ្នកប្រើបំពានគ្រឿងញៀន**នៅក្នុងឃុំចំនួន៦០ នៃខេត្តក្រុងទាំង១២ដែលទទួលរងផលប៉ះពាល់គ្រឿងញៀនធ្ងន់ធ្ងររួចមក បច្ចុប្បន្ននេះបាននិងកំពុងបន្តការកសាងសមត្ថភាពនៅក្នុងប្រព័ន្ធសេវាសុខភាពនិងសង្គមកិច្ច ដើម្បីរៀបចំផែនការផ្តល់ការព្យាបាលផ្អែកលើសហគមន៍លើការប្រើបំពានសារធាតុញៀននិងការស្តារនីតិសម្បទារួមជាមួយការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍សេវាព្យាបាលនិងថែទាំសំរាប់អ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់គេ ។

ខេត្ត-ក្រុងនីមួយៗក្នុងចំណោមខេត្ត-ក្រុងទាំង១២ខាងលើ បានជ្រើសយកឃុំចំនួនពីរដែល

មានអ្នកប្រើគ្រឿងញៀនច្រើនជាងគេ ដើម្បីពិភាក្សាជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ក្រុង, ស្រុក-ខណ្ឌ,សង្កាត់-ឃុំ ព្រមទាំងមានការចូលរួមពីមន្ទីរពេទ្យបង្អែក,មណ្ឌលសុខភាពដើម្បី បញ្ចុះផែនការអន្តរាគមន៍ លើការព្យាបាលអ្នកញៀននៅតាមគ្រួសារសហគមន៍ ឬ តាមមជ្ឈមណ្ឌល ព្យាបាលនានា ។ បន្ទាប់មក គំរោងនឹងអនុវត្តកម្មវិធីចុះសួរសុខទុក្ខជនរងគ្រោះដោយគ្រឿងញៀននៅ តាមផ្ទះ សហគមន៍ ឬមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទានានា និងធ្វើការបណ្តុះបណ្តាលមន្ត្រីទាំង នោះនូវវិធីបន្សាបជាតិញៀន និង ផលិតឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការងារព្យាបាល / ស្តារនីតិ សម្បទានេះ ។

## ៥-នីតិកម្ម និង ផែនការ

### ក-នីតិកម្ម

ឆមាសទី១ឆ្នាំ២០០៨នេះ ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជា សមាជិកនៃពិធីសារឆ្នាំ១៩៧២ ដែលពិធីសារនេះបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ត្រូវបានព្រះមហាក្សត្រប្រទានសច្ចាប័ន ។ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនលិខិតុបករណ៍ទៅអង្គការសហប្រជាជាតិ និងបានផ្ញើជូនទៅគ្រប់ឯកអគ្គរាជទូត រដ្ឋទូត អគ្គ-កុងស៊ុល និងកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ដែលប្រចាំនៅបណ្តាប្រទេសនានា ។

ក្រៅពីនោះ តាមរយៈក្រុមការងារនីតិកម្ម អគ្គលេខាធិការដ្ឋាន អជបគញ កំពុងបន្តការ កសាងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន ។

### ខ-ផែនការ

-អគ្គលេខាធិការដ្ឋាន អជបគញ បានសហការសិរបសិរួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីវិនិយោគសាធារណៈ(២០០៩-២០១១)សំរាប់កិច្ចប្រជុំពិគ្រោះយោបល់**C-G**ប្រចាំឆ្នាំ ។

-អគ្គលេខាធិការដ្ឋាន ដោយមានកិច្ចសហការល្អជាមួយក្រសួងសមាជិក អជបគញ, ក្រសួង ពាក់ព័ន្ធនានា, អង្គការជាតិនិងអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាល បានបន្តយកចិត្តទុកដាក់អនុវត្តនូវ ផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនប្រចាំឆ្នាំ២០០៨សំខាន់លើការអភិវឌ្ឍន៍ធនធាន មនុស្សតាមរយៈការបណ្តុះបណ្តាលភាសាអន្តរជាតិ កុំព្យូទ័រ ការបណ្តុះបណ្តាលជំនាញអនុវត្តច្បាប់ និង ការងារអប់រំផ្សព្វផ្សាយលើកកំពស់ការយល់ដឹងពីគ្រឿងញៀន សំរេចលទ្ធផលបានប្រមាណ៤០%នៃ ផែនការប្រចាំឆ្នាំ២០០៨នេះ ។

## ៦-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងឆមាសទី១ឆ្នាំ២០០៨នេះ អគ្គលេខាធិការដ្ឋាន អជបគញ បានយកចិត្តទុកដាក់បន្តលើកិច្ច សហប្រតិបត្តិការអន្តរជាតិទាំងក្នុងលក្ខណៈទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍ ទាំងនៅក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ តាមរយៈកិច្ចប្រជុំ និង ការអនុវត្តន៍នូវកម្មវិធីគំរោងនានា រួមមាន :

-កិច្ចប្រជុំប្រចាំឆ្នាំ ទ្វេភាគីថ្នាក់រដ្ឋមន្ត្រី (កម្ពុជា-វៀតណាម), ទ្វេភាគីថ្នាក់រដ្ឋមន្ត្រី (កម្ពុជា-ឡាវ) និងកិច្ចប្រជុំត្រីភាគីថ្នាក់រដ្ឋមន្ត្រី (កម្ពុជា-វៀតណាម-ឡាវ) លើកទី៧ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនដែលបានប្រព្រឹត្តទៅនៅខេត្តសៀមរាប (០៤-០៧/១២/២០០៧) ។ នៅក្នុងកិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រីកម្ពុជា-វៀតណាម និង ទ្វេភាគីថ្នាក់រដ្ឋមន្ត្រីកម្ពុជា-ឡាវ បានចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ សារធាតុគីមីផ្សំគ្រឿងញៀន និង នៅក្នុងកិច្ចប្រជុំត្រីភាគីថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម បានធ្វើការអនុម័តលើសេចក្តីថ្លែងការណ៍រួម និង សេចក្តីប្រកាសព័ត៌មាន ។

-សន្និសីទអាស៊ាន+កូរ៉េ ស្តីពីបញ្ហាគ្រឿងញៀន (សាធារណរដ្ឋកូរ៉េ២០-២២/០១/២០០៨) ។

-កិច្ចប្រជុំផ្តល់ប្រឹក្សាអាស៊ីលើកទី១ ស្តីពីភាពក្រីក្រ ការប្រើប្រាស់គ្រឿងញៀន និង មេរោគអេដស៍/ជម្ងឺអេដស៍ (ឥណ្ឌា ថ្ងៃទី២៦-៣១/០១/២០០៨) ។

-សន្និសីទអន្តរជាតិលើកទី១៣ ស្តីពីបញ្ហាគ្រឿងញៀន "**ADEC-13**" (តូក្យូ ប្រទេសជប៉ុន ថ្ងៃទី២៩/០១-០១/០២/២០០៨) ។

-វគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតមន្ទីរពិសោធន៍ផលិតគ្រឿងញៀនលួចលាក់ (សាលាជំនាញអនុវត្តច្បាប់អន្តរជាតិ " **ILEA**" (បាងកក ប្រទេសថៃ ២១-៣១/០១/២០០៨) ។

-កិច្ចប្រជុំលើកទី៤ នៃក្រុមសហប្រតិបត្តិការអាស៊ីដើម្បីត្រួតពិនិត្យការបង្វែរសារធាតុគីមីផ្សំ (**ACoG**) និងសន្និសីទលើកទី៤ ស្តីពីសារធាតុគីមីផ្សំសំរាប់ផលិតគ្រឿងញៀន**ATS**"**IFCP**" (តូក្យូ ១២-១៥/០២/២០០៨) ។ កិច្ចប្រជុំ បានផ្តោតសំខាន់ទៅលើ **១)** ទិដ្ឋភាពច្បាប់ដើម្បីធានាដល់ការចោទប្រកាន់និងផ្តន្ទាទោសបទល្មើសពាក់ព័ន្ធនឹងសារធាតុគីមីផ្សំ **២)** ចាត់ឱ្យមានមន្ត្រីទំនាក់ទំនងដើម្បីចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មាន **៣)** រៀបចំបញ្ជីតាមដានសារធាតុគីមីផ្សំ ដែលច្បាប់មិនបានធ្វើការត្រួតពិនិត្យ ហើយឃើញមានប្រើប្រាស់នៅក្នុងមន្ទីរពិសោធន៍លួចលាក់ **៤)** លើកកំពស់ការយល់ដឹងអំពីការបង្វែរសារធាតុគីមីផ្សំដល់ក្រុមហ៊ុនឧស្សាហកម្មគីមីនានា ដើម្បីគេចូលរួមសហការជាមួយសមត្ថកិច្ច **៥)** ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ក្នុងការវិភាគសារធាតុគីមីផ្សំ និងជំនាញក្នុងការបំផ្លាញប្រកបដោយសុវត្ថិភាពនូវគ្រឿងញៀននិងសាធាតុគីមីផ្សំ **៦)** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យមានប្រសិទ្ធិភាព ។

-កិច្ចប្រជុំគំរោង ស្តីពីសហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍន៍ដំណាំជំនួសដោយបំបាត់ចោលនូវដំណាំអាភៀន នៅអាស៊ីអាគ្នេយ៍ "គំរោង**H84**" (បាងកក ប្រទេសថៃ ២៧-២៨/៣/២០០៨) ។

-កិច្ចប្រជុំ ស្តីពីការធ្វើតេស្តសាកល្បងលើក្បួនសំរាប់បណ្តុះបណ្តាលអំពីការប្រើបំពានគ្រឿងញៀន **ATS** (ក្រាប៊ី ប្រទេសថៃ ២៥-២៨/៣/២០០៨) ។

-សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការចូលរួមរបស់ឧស្សាហកម្មគីមីក្នុងការបង្ការការបង្វែរសារ-ធាតុគីមីផ្សំ (កូឡាឡាំពួរ ម៉ាឡេស៊ី ២៥-២៧/៣/២០០៨) ដែលមានគោលបំណង **១)** បង្កើតភាពជាដៃ

គូរវាងរដ្ឋាភិបាលជាមួយក្រុមហ៊ុនឧស្សាហកម្មគីមីដើម្បីត្រួតពិនិត្យការបង្វែរសារធាតុគីមី តាមរយៈការរៀបចំនូវខិត្តប័ណ្ណ ផ្ទាំងរូបភាព ស្តីពីសារធាតុគីមីផ្សំ, ការរៀបចំ**LOGO**សំរាប់ក្រុមហ៊ុនឧស្សាហកម្មគីមីប្រើប្រាស់ **២)** ការដាក់បញ្ចូលបញ្ហាសារធាតុគីមីផ្សំទៅក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការសរសើរលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលគ្រប់គ្រងសារធាតុគីមីផ្សំបានល្អ ។

–សិក្ខាសាលាបណ្តុះបណ្តាលសំរាប់យុវជនស្តីពីការអភិវឌ្ឍន៍សង្គមនិងការបង្ការការប្រើបំពានគ្រឿងញៀន (២៣–៣១/៣/២០០៨ខេត្តឈាងរ៉ៃប្រទេសថៃ) ។ សិក្ខាសាលានេះ ទទួលបាននូវចំណេះដឹងអំពីតួនាទីរបស់យុវជនក្នុងការអភិវឌ្ឍន៍សង្គម ការអប់រំបង្ការបញ្ហាគ្រឿងញៀននិងការរៀបចំផែនការសកម្មភាពពាក់ព័ន្ធនឹងការងារអប់រំបង្ការ និងការស្វែងរកដៃគូគាំទ្រ ។

–តាមរយៈ គំរោងស្តីពីការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូនៃប្រទេសជាសមាជិក **MOU** ក្នុងតំបន់អាស៊ីប៉ូពាំ (គំរោង**H15**) និងគំរោងស្តីពីការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ (គំរោង**J11**) របស់ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម អ.ស.ប អគ្គលេខាធិការដ្ឋាន អជបគញ បានទទួលធ្វើជាម្ចាស់ផ្ទះនៃសិក្ខាសាលា ស្តីពីការអនុវត្តន៍ជាមូលដ្ឋាននូវអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន សំរាប់បណ្តាប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គនិងប្រទេសនៅក្នុងសមាគមអាស៊ាន (សណ្ឋាគារសាន់វេ ភ្នំពេញ ថ្ងៃ០៧–១០/៤/២០០៨) ។

–កិច្ចសហការនិងសម្របសម្រួលជូនប្រតិភូនៃក្រុមទូរទស្សន៍របស់អង្គការសហប្រជាជាតិ ដើម្បីបំពេញទស្សនកិច្ចនិងថតយកសកម្មភាពសំខាន់ៗ ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន និងការងារអប់រំព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅ មន្ទីរប្រឆាំងគ្រឿងញៀន មជ្ឈមណ្ឌលឱកាសខ្ញុំ និង ការិយាល័យទំនាក់ទំនងព្រំដែនខេត្តស្ទឹងត្រែង (២២–២៤/៤/២០០៨) ។

–កិច្ចប្រជុំមន្ត្រីទំនាក់ទំនងគំរោង**H15** (ក្រុងវៀងច័ន្ទ២៣–២៤/៥/២០០៨) និងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ នៃបណ្តាប្រទេសជាសមាជិកហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នា (**MOU**) ឆ្នាំ ១៩៩៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ក្រុងវៀងច័ន្ទថ្ងៃទី១១–១៣/៦/២០០៨) បានឯកភាពគ្នាលើបញ្ហាសំខាន់ៗរួមមាន **១)** ការគាំទ្រលើគំនិតផ្តួចផ្តើមគំរោងស្តីពី"ការលើកកំពស់សមត្ថភាព និងការសម្របសម្រួលជាអន្តរជាតិស្តីពីការស៊ើបអង្កេត និងចោទប្រកាន់បទល្មើសគ្រឿងញៀន នៅក្នុងប្រទេស កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម **២)** ធ្វើការផ្លាស់ប្តូរផ្នែកច្បាប់នៃបណ្តាប្រទេសជាសមាជិក**MOU** **៣)** ពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន (**BLO**) ដើម្បីឆ្លើយតបនិន្នាការគ្រឿងញៀន ហើយតាមរយៈគំរោង**I61**របស់**UNODC**នឹងផ្តល់សម្ភារៈប្រតិបត្តិការបន្ថែម (ពិសេសមធ្យោបាយធ្វើដំណើរនិងមធ្យោបាយទាក់ទង) **៤)** ធ្វើការកែសំរួលនិងបំពាក់កម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធកុំព្យូទ័រ (**CBT**) សំរាប់មន្ត្រីនៅគ្រប់ការិយាល័យទំនាក់ទំនងព្រំដែន **៥)** លើកកំពស់កិច្ចសហប្រតិបត្តិការរួម សំរាប់ការិយាល័យទំនាក់ទំនងព្រំដែនដែលស្ថិតនៅក្នុងតំបន់មានមហន្តរាយខ្ពស់ (ពិសេសការត្រួតពិនិត្យរួមនៅតាមដងទន្លេមេគង្គ) ។

-សិក្ខាសាលា និង ទស្សនកិច្ចសិក្សាស្វែងយល់ លើការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលគំរូ (ក្រុងហូជីមិញ វៀតណាម ២១-២៥/៤/២០០៨) ។

-សិក្ខាសាលា គំរោងគាំទ្រវិទ្យាសាស្ត្រដើម្បីពង្រឹងការត្រួតពិនិត្យគ្រឿងញៀន**ATS** និងសារធាតុគីមីផ្សំ (នៅទីក្រុងបាងកក១២-១៤/១២/២០០៧) ដើម្បីបង្កើតបណ្តាញនិងធ្វើឱ្យប្រសើរឡើងនូវការផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានរវាងបណ្តាមន្ទីរពិសោធន៍តំបន់អាស៊ី អឺរ៉ុប និង អូសេអានី ដោយផ្តោតសំខាន់ទៅលើការបញ្ចូលទិន្នន័យ គុណភាពរបស់ទិន្នន័យ និង និរន្តរភាពរបស់បណ្តាញ ។

-សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការព្យាបាលអ្នកប្រើបំពានគ្រឿងញៀន**ATS** (ទីក្រុងហាណូយ វៀតណាម ១៦-២០/៦/២០០៨) ។

## III / <u>**ការសន្និដ្ឋាន**</u> :

៦ខែដើមឆ្នាំ២០០៨នេះ យើងបានបន្តការខិតខំប្រឹងប្រែងយ៉ាងសកម្មដើម្បីទប់ស្កាត់ការហូរចូលគ្រឿងញៀនពីតំបន់ព្រំដែន ធ្វើឱ្យបរិមាណគ្រឿងញៀនដែលរឹបអូសបាននៅក្នុងប្រទេសមានការថយចុះបើប្រៀបធៀបទៅនឹងឆមាសទី១ឆ្នាំ២០០៧កន្លងទៅ ។ ជាមួយនេះ ដោយមានកិច្ចសហការល្អជាមួយបណ្តាក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល, អង្គការជាតិនិងអន្តជាតិ ក៏ដូចអង្គការមិនមែនរដ្ឋាភិបាលនានា យើងបានបន្តយកចិត្តទុកដាក់លើកកំពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀនទាំងនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ ទាំងនៅក្នុងស្រទាប់ប្រជាជន/មហាជន ដោយបានចលនាឱ្យមានការចូលរួមក្នុងការងារបង្ការការពារនិងកាត់បន្ថយនូវតម្រូវការគ្រឿងញៀន ធ្វើឱ្យអត្រាអ្នកប្រើបំពានគ្រឿងញៀនក្នុងឆមាសទី១នេះធ្លាក់ចុះពីកំរិតអតិបរិមា ។

ប៉ុន្តែដោយសារនិន្នាការគ្រឿងញៀន ទាំងនៅក្នុងតំបន់និងអន្តរជាតិ (ពិសេសតំបន់ត្រីកោណមាសនិងតំបន់អឌ្ឍច័ន្ទមាស) កំពុងមានការវិវត្តន៍កើនឡើងនូវការផលិតគ្រឿងញៀនខុសច្បាប់ បានជះឥទ្ធិពលនៃការចរាចរគ្រឿងញៀនមកលើបណ្តាប្រទេសជាច្រើននៅលើពិភពលោក ។

នៅកម្ពុជា ទោះបីការហូរចូលគ្រឿងញៀនពីតំបន់ព្រំដែនត្រូវបានទប់ស្កាត់ឱ្យមានការថយចុះ ប៉ុន្តែបានកើតមាននូវចំណុចប្រឈមថ្មីៗមួយចំនួន ជាក់ស្តែងក្រៅពីខេត្តស្ទឹងត្រែងដែលជាខេត្តធ្លាប់បានកត់សំគាល់ យើងក៏បានពិនិត្យឃើញមានខេត្តនៅភាគខាងជើងមួយចំនួនដែលពីមុនមកពុំធ្លាប់មានការហូរចូលគ្រឿងញៀន ឥឡូវនេះកំពុងមានសញ្ញាកើតឡើង ។ អាចនិយាយម្យ៉ាងទៀតថា ពួកឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិនៅតែបន្តរិះរកគ្រប់វិធីក្នុងការនាំគ្រឿងញៀនចូលមកកម្ពុជា រួមទាំងការព្យាយាមយកកម្ពុជាធ្វើជាកន្លែងផលិតគ្រឿងញៀនសំយោគ ។

ការប្រើបំពានគ្រឿងញៀន ទោះបីត្រូវបានកាត់បន្ថយមកនៅក្នុងកំរិតអប្បបរមា ប៉ុន្តែការប្រើប្រាស់បានរាលដាលទៅតាមខេត្ត-ក្រុងមួយចំនួនដែលពីមុនមកពុំធ្លាប់មាន ហើយប្រការដែលគួរកត់សំគាល់ គឺមានការកើនឡើងនូវការប្រើប្រាស់គ្រឿងញៀនប្រភេទហេរ៉ូអ៊ីន ដែលទាមទារឱ្យមានការព្យាបាលដោយប្រើសារធាតុជំនួស (កម្មវិធីមេតាដូន) ហើយកម្មវិធីនេះគឺជាកម្មវិធីព្យាបាលថ្មីសំរាប់

ប្រទេសកម្ពុជា ។ ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល ចាំបាច់ត្រូវតែបង្កើន និង លើកកំពស់កិច្ចប្រតិបត្តិការរុករកនិងបង្ក្រាប និងធ្វើការអភិវឌ្ឍន៍ធនធានមនុស្សដោយឈរលើមូលដ្ឋាន ពង្រឹងសមត្ថភាព, មុខជំនាញឯកទេស, ការបំពាក់សម្ភារៈបច្ចេកទេស, ការត្រួតពិនិត្យនិងកែលំអគុណភាពការងារ និងការពង្រឹងពង្រីកភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសនៅក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ ។

## IV / ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី២ ឆ្នាំ២០០៨ :

យោងផែនការសកម្មភាពឆ្នាំ២០០៨ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អជបគញ នឹងបន្តអនុវត្តតាមយុទ្ធសាស្ត្រទាំង៥ស្តីពីការត្រួតពិនិត្យគ្រឿងញៀនគឺ :

**១–កាត់បន្ថយនិងឈានទៅលុបបំបាត់ទាំងស្រុងនូវតម្រូវការគ្រឿងញៀន ។**

**២–កាត់បន្ថយនិងឈានទៅលុបបំបាត់ទាំងស្រុងនូវការផ្គត់ផ្គង់គ្រឿងញៀន ។**

**៣–ពង្រឹងការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀន ។**

**៤–កាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។**

**៥–ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ។**

**ចំពោះមុខ** អគ្គលេខាធិការដ្ឋាន អជបគញ នឹងបន្តសហការសម្របសម្រួលជាមួយក្រសួងស្ថាប័នរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធដើម្បីអនុវត្តនូវរាល់កិច្ចការដែលនៅសេសសល់ ហើយដែលបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពឆ្នាំ២០០៨នេះ ក៏ដូចជាគោលការណ៍ណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ ដូចតទៅ :

### ១-ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ

១.១–បន្តកិច្ចសហការជាមួយ**UNODC**ក្នុងការអនុវត្តគំរោង**KHM/J11** ស្តីពីការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ ក្នុងនោះនឹងធ្វើឱ្យកាន់តែប្រសើរឡើងនូវគេហទំព័រ **(Web-site)** របស់អគ្គលេខាធិការដ្ឋានទាំងភាសាខ្មែរនិងភាសាអង់គ្លេស សំរាប់ដៃគូអន្តរជាតិនានាងាយតាមដានសភាពការណ៍គ្រឿងញៀននៅកម្ពុជា ។

១.២–ចងក្រងឯកទេសនីតិវិធីតាមបទដ្ឋានបច្ចេកទេសដែលមានសុវត្ថិភាពសំរាប់ប្រតិបត្តិការបង្ក្រាបមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

១.៣–ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០០៧ ស្តីពីទិន្នន័យគ្រឿងញៀនខុសច្បាប់ និងប្រព័ន្ធតាមដានជាប្រចាំនៅកម្ពុជា ។

### ២-ការងារអប់រំផ្សព្វផ្សាយ និង បង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន

២.១–បន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពក្រុមការងារគ្រឿងញៀន/អេដស៍ (**D/HA**) ។

២.២–ខិតខំពង្រឹងក្រុមការងារប្រមូលទិន្នន័យអ្នកប្រើគ្រឿងញៀននៅតាមខេត្ត–ក្រុង (**PDCC**) ។

២.៣–បន្តកិច្ចសហការជាមួយក្រសួង–ស្ថាប័ន, អង្គការអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាលដែល

ពាក់ព័ន្ធ ដើម្បីលើកកំពស់ការយល់ដឹងពីគ្រឿងញៀន/អេដស៍ ។

២.៤–បន្តជំរុញការតាមដានការអនុវត្តន៍កម្មវិធីម្ទុល/ស៊ីរាំង នៅកម្ពុជា ។

២.៥–បន្តសហការនិងជំរុញការអនុវត្តន៍កម្មវិធីលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន នៅតាមគ្រឹះស្ថានសិក្សា, ក្រសួង–ស្ថាប័ន, រោងចក្រ/សហគ្រាស និង សហគមន៍ ។

២.៦–ត្រៀមការងារអប់រំផ្សព្វផ្សាយ សំរាប់ព្រះរាជពិធីបុណ្យជាតិធំៗ (បុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ, បុណ្យឯករាជ្យជាតិ, បុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ....) និងទិវាបុណ្យអន្តរជាតិនានា ។

**៣–ការងារអនុវត្តច្បាប់**

៣.១–បន្តពង្រឹងយុទ្ធនាការលុបបំបាត់ការដាំដុះដំណាំកញ្ឆា ។

៣.២–លើកកំពស់ការយល់ដឹងអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៣–បន្តពង្រឹងនិងពង្រីកយន្តការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយកុំព្យូទ័រ (CBT) ។

៣.៤–បន្តសហការជាមួយអង្គការJICA អនុវត្តគំរោងស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

៣.៥–បន្តសហការជាមួយ**UNODC** ក្នុងការអនុវត្តន៍ :

–គំរោង**I61** ស្តីពីយន្តការនៃការរួមបញ្ចូលគ្នាដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀតសំរាប់ការិយាល័យទំនាក់ទំនងគ្រឿងញៀននៅព្រំដែន ក្នុងតំបន់អាស៊ីបូព៌ា ។

–គំរោង **XAP/I 63** ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ ។

៣.៦–ចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានទិន្នន័យសារធាតុគីមីផ្សំ ដែលរៀបចំឡើងដោយនាយកដ្ឋានត្រួតពិនិត្យគ្រឿងញៀននៃក្រសួងសុខាភិបាលជប៉ុន ។

៣.៧–បន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

៣.៨–ជំរុញអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (**ONCB**) លើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន ។

៣.៩–បន្តកិច្ចសហប្រតិបត្តិការជាមួយភាគីកូរ៉េ អនុវត្តគំរោងស្តីពី "ការផ្តល់សមត្ថភាពជំនាញត្រួតពិនិត្យគ្រឿងញៀនដល់មន្ត្រីអនុវត្តន៍ច្បាប់នៅបណ្តាប្រទេសក្នុងសមាគមអាស៊ាន" នៅកម្ពុជា ។

**៤–ការងារទិន្នន័យព័ត៌មានគ្រឿងញៀន**

៤.១–បន្តការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀននៅគ្រប់ខេត្ត–ក្រុង និង ស្ថាប័នពាក់ព័ន្ធ ។

៤.២–បន្តសហការជាមួយអង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធ៌មនៃអង្គការសហប្រជាជាតិ (**the United Nation Educational Scientific Cultural Organization. UNESCO)** រៀបចំរបាយការណ៍ស្តីពីសេវាកម្មកាត់បន្ថយតម្រូវការ និង ការកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រឿងញៀន នៅកម្ពុជា និងតម្រូវការបណ្តុះបណ្តាលពីបញ្ហាគ្រឿងញៀនក្នុងចំណោមស្ថាប័នសិក្សា ។

៤.៣–បន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍សើរស្បែកនិងកាមរោគ (**NCHADS**)

នៃក្រសួងសុខាភិបាល, ក្នុងការធ្វើរបាយការណ៍ស្តីពីលទ្ធផលអង្កេតពីអត្រាអ្នកមានមេរោគអេដស៍ក្នុងចំណោមអ្នកប្រើគ្រឿងញៀន ។

៤.៤–បន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើរស្បែក និង កាមរោគនៃក្រសួងសុខាភិបាល, អង្គការសុខភាពពិភពលោក(**WHO**), អង្គការកសាង, អង្គការមិត្តសំឡាញ់និងវិទ្យាស្ថាន **Burnet** របស់អូស្ត្រាលីក្នុងការអង្កេតលើឥរិយាបថនៃការប្រើគ្រឿងញៀន**ATS** ។

**៥–ការងារព្យាបាល**

៥.១–បន្តសហការអនុវត្តគំរោង **H83** របស់**UNODC** ស្តីពីការអភិវឌ្ឍន៍លើសេវាប្រឹក្សាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនផ្អែលើសហគមន៍ជាមូលដ្ឋាន ក្នុងនោះការងារបន្ទាន់គឺការជ្រើសរើសយកឃុំចំនួន២នៃខេត្ត–ក្រុងនីមួយៗក្នុងចំណោមខេត្ត–ក្រុងទាំង១២ដែលទទួលរងផលប៉ះពាល់គ្រឿងញៀនធ្ងន់ធ្ងរ ដើម្បី :

–ផ្តល់ការកសាងសមត្ថភាពនៅក្នុងប្រព័ន្ធសេវាសុខភាពនិងសង្គមកិច្ច ។

–រៀបចំផែនការផ្តល់ការព្យាបាលផ្អែកលើសហគមន៍លើការប្រើបំពានសារធាតុញៀន និងការស្តារនីតិសម្បទា រួមជាមួយការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ សេវាព្យាបាលនិងថែទាំសំរាប់អ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់គេ ។

**៦–នីតិកម្ម**

៦.១–បន្តជំរុញការរៀបចំគោលនយោបាយជាតិស្តីពីការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៦.២–បន្តជំរុញការរៀបចំបណ្តាលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យគ្រឿងញៀន ។

**៧–សហប្រតិបត្តិការអន្តរជាតិ**

៧.១–ត្រៀមលក្ខណៈសំរាប់ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា(**MOU**)ទ្វេភាគី កម្ពុជា–ចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុគីមីផ្សំ (ខែ៩/២០០៨)។

៧.២–ត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំទ្វេភាគី / ត្រីភាគី កម្ពុជា–វៀតណាម–ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន លើកទី៨ (ខែ៨/២០០៨) ។

៧.៣–ត្រៀមទៅចូលរួមនៅក្នុងកិច្ចប្រជុំក្រុមការងារទី១, ទី២ នៃគំរោង**ACCORD**របស់**UNODC** និង លេខាធិការដ្ឋានអាស៊ាន (០៨–១២/៧/២០០៨)នៅទីក្រុងហូជីមិញ វៀតណាម ។

៧.៤–ត្រៀមទៅចូលរួមនៅក្នុងកិច្ចប្រជុំក្រុមការងារទី៣, ទី៤ នៃគំរោង**ACCORD**របស់**UNODC** (១៦–១៩/៧/២០០៨)នៅប្រទេសហ្វីលីពីន ។

៧.៥–បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ នៅប្រទេសថៃ (ខែសីហាឆ្នាំ២០០៨) ។

៧.៦–បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ចូលរួមក្នុងសិក្ខាសាលាស្តីពី ការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅខេត្តយូណាន់ប្រទេសចិន (ខែកញ្ញាឆ្នាំ២០០៨) ។

៧.៧–ត្រៀមចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីបញ្ហាគ្រឿងញៀន (**ASOD**) លើកទី២៩ ។

៧.៨–ត្រៀមចូលរួមកិច្ចប្រជុំត្រីភាគី កម្ពុជា–ឡាវ–ថៃ លើកទី១ នៅប្រទេសថៃ ។

៧.៩–ត្រៀមបញ្ជូនមន្ត្រីជំនាញវិភាគគ្រឿងញៀនទៅចូលរួមវគ្គបណ្តុះបណ្តាលការវិភាគគ្រឿងញៀន **ATS** នៅទីក្រុងហាណូយប្រទេសវៀតណាម ។

៧.១០–ត្រៀមបញ្ជូនមន្ត្រីទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅទីក្រុងហូជីមិញប្រទេសវៀតណាម ។

៧.១១–ត្រៀមអញ្ជើញប្រតិភូវៀតណាមមកកម្ពុជា ដើម្បីពិភាក្សាលើលទ្ធភាពផ្តល់មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដល់កម្ពុជា ។

៧.១២–ត្រៀមបញ្ជូនមន្ត្រីទៅចូលរួមទស្សនកិច្ចសិក្សា ស្តីពីការព្យាបាលអ្នកប្រើគ្រឿងញៀន**ATS** នៅប្រទេសអូស្ត្រាលី (២១–២៥/៧/២០០៨) ។

៧.១៣–ត្រៀមលក្ខណៈចូលរួមក្នុងសកម្មភាពត្រួតពិនិត្យគ្រឿងញៀនក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី ទាំងនៅក្នុងតំបន់និងអន្តរជាតិ ។

ក្រៅពីទិសដៅខាងលើ អគ្គលេខាធិការដ្ឋាននឹងត្រៀមអនុវត្តនូវរាល់គោលការណ៍ណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ ដើម្បីឆ្លើយតបសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល ។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

-ខុទ្ទកាល័យ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ**

-ឯកឧត ្តម អនុប្រធានអចិន្រៃ ្តយ៍ អ.ជ.ប.គ.ញ

-ក្រសួងសមាជិក អ.ជ.ប.គ.ញា

-ក្រសួងផែនការ

(ដើម្បីជូនជ្រាប)

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

-អគ្គលេខាធិការរង អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង

-នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ